**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ភាគីដាក់ឯកសារ:** សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី

**ដាក់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 18-Mar-2016, 14:20
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ:** **សាធារណៈ/Public**

**ឋានៈនៃចំណាត់ថ្នាក់ឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

---

**សារណារបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្តីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គឹមសួន

គីម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

Original EN: 01211543-01211554

សំ សុគង់

យ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI
Beini Ye

ផ្ញើជូន៖

ការិយាល័យសហព្រះរាជអាជ្ញា៖

ជា លាង

Nicholas KOUMJIAN

ជនជាប់ចោទ៖

ខៀវ សំផន

នួន ជា

សហមេធាវីការពារក្តី៖

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

មេធាវីប្រចាំការ៖

ទូច វរល័ក្ស

Calvin SAUNDERS

សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖

Olivier BAHOUGNE
Patrick BAUDOUIN

## I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី (សហមេធាវីនាំមុខ) សូមដាក់សារណានេះ ដើម្បីស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការបញ្ជាក់បំភ្លឺទៅលើផ្នែកនៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើង "ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់" ចុះថ្ងៃ ទី ២៥ ខែ មេសា ឆ្នាំ ២០១៤ ចំពោះបញ្ហាថ្មីៗ ដែលបានលើកឡើងនៅក្នុងតុលាការ និងនៅក្នុងសារណាជាលាយលក្ខណ៍អក្សរ អំពីវិសាលភាពនៃការចោទប្រកាន់ទាក់ទងនឹងការរំលោភផ្លូវភេទនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[1]។ សហមេធាវីនាំមុខ ស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការបញ្ជាក់បំភ្លឺថាតើអង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្តឹងអំពីការចោទប្រកាន់ផ្នែកអង្គហេតុទាក់ទងនឹងការរំលោភផ្លូវភេទ នៅក្នុងវិសាលភាពក្នុងសំណុំរឿង ០០២/០២ រួមមាន សហករណ៍ត្រាំកក់ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ដែរ ឬទេ។

## II. ច្បាប់ជាធរមាន

2. មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា៖

"ចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ចៅក្រមស៊ើបសួរត្រូវស៊ើបសួរតែអង្គហេតុនោះប៉ុណ្ណោះ។

ប្រសិនបើមានលេចអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា អាចប្តឹងសុំទៅចៅក្រមស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ប្រសិនបើអង្គហេតុនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង។"

---

[1] សម្រាប់គោលបំណងនៃសារណានេះ ប្រសិនបើពុំមានការបញ្ជាក់ច្បាស់ទេនោះ ការប្រើប្រាស់ពាក្យ "ការរំលោភសេពសន្ថវៈ" សំដៅទៅលើការរំលោភលើផ្លូវភេទនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ។ សហមេធាវីនាំមុខ ក៏បញ្ជាក់ភាពខុសគ្នារវាងពាក្យ "ការរំលោភសេពសន្ថវៈ" (ដែលសំដៅទៅលើអំពើ និងការប្រព្រឹត្ត) និង "ការរំលោភសេពសន្ថវៈ" (ដែលសំដៅទៅលើលក្ខណៈច្បាប់នៃអំពើ និងការប្រព្រឹត្តិបែបនោះ ជាការចោទប្រកាន់ឧក្រិដ្ឋកម្មមួយ)។

3. វិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"។

4. វិធាន ៥៥ (៣) នៃវិធានផ្ទៃក្នុង ចែងថា "ក្នុងអំឡុងពេលស៊ើបសួរ ប្រសិនបើមានលេចចេញអង្គហេតុថ្មី សហចៅក្រមស៊ើបអង្កេត ត្រូវជូនព័ត៌មានដល់សហព្រះរាជអាជ្ញា លើកលែងតែអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសនៃអង្គហេតុដែលមានកំណត់នៅក្នុងដីកាសន្និដ្ឋាន ដែលមានស្រាប់។ កាលណាអង្គហេតុថ្មីនេះ ត្រូវបានបញ្ជូនទៅឲ្យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតគ្មានអំណាចធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះបានឡើយ លុះត្រាតែទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពីសហព្រះរាជអាជ្ញា"។

5. មាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថា ចៅក្រមស៊ើបសួរ បិទការស៊ើបសួរ តាមរយៈដីកាបញ្ជូនរឿងជំនុំជម្រះ ឬដីកាលើកលែងការចោទប្រកាន់។ មាត្រានេះចែងថា "ដីកាលើកលែងការចោទប្រកាន់" អាចចេញបាន ប្រសិនបើ និង/ឬ នៅពេលដែល "អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ" ឬ "គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ"។ យោងតាមមាត្រា ២៧៧ "ដីកាលើកលែងការចោទប្រកាន់" អាចប្តឹងឧទ្ធរណ៍បាន។

6. ស្រដៀងគ្នានេះដែរ វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាលើកលែងការចោទប្រកាន់" ត្រូវបានចេញដោយសហចៅក្រមស៊ើបអង្កេត ប្រសិនបើ និងនៅពេលដែល "អំពើដែលចោទប្រកាន់មិនរាប់ចូលជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ" ឬ "ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ"។ វិធាន ៦៧(៤) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាដំណោះស្រាយ ត្រូវតែមានសំអាងហេតុ។ ដីកានេះអាចជាដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះចំពោះអំពើមួយចំនួន ឬប្រឆាំងនឹងបុគ្គលមួយចំនួន និងអាចជាដីកាលើកលែងចោទប្រកាន់ចំពោះករណីដទៃទៀត"។ វិធាន ៦៦ ស្ទួនពីរ(១) នៃវិធានផ្ទៃក្នុង ចែងថា "នៅពេលជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរដោយដកចេញនូវអង្គហេតុមួយចំនួន ដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"។ យោងតាមវិធាន ៦៦ស្ទួន(៤) សេចក្តីសម្រេចធ្វើឡើងពាក់ព័ន្ធនឹងវិធាននេះ បើកផ្លូវប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង។

7. សហចៅក្រមស៊ើបអង្កេតអាចធ្វើសេចក្ដីសម្រេច ទាក់ទងនឹងអង្គហេតុទាំងអស់ដែលខ្លួនទទួលបានបណ្ដឹង និងការកំណត់ប្រភេទបទល្មើសដែលពាក់ព័ន្ធ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា ដោយ (១)ត្រូវបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីបានចោទប្រកាន់ពួកគេ ឬ (២) ចេញដីកាលែកលែងការចោទប្រកាន់ ចំពោះអង្គហេតុទាំងមូល ឬតាមផ្នែក[2]។ វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ចែងថា "ដីកាដំណោះស្រាយបើកផ្លូវឲ្យប្ដឹងឧទ្ធរណ៍ ដូចមានចែងក្នុងវិធាន ៧៤ នៃវិធានផ្ទៃក្នុង"។

8. វិធាន ៩៨(២) នៃវិធានផ្ទៃក្នុង ចែងថា "សាលក្រម ត្រូវតែសម្រេចត្រឹមអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះ អាចផ្លាស់ប្ដូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទឡើយ"។ លើសពីនេះ វិធាន ៩៨(៣) នៃវិធានផ្ទៃក្នុង ចែងថា "អង្គជំនុំជម្រះត្រូវពិនិត្យថាតើអំពើនោះជាបទឧក្រិដ្ឋ ដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងថាតើជនជាប់ចោទបានប្រព្រឹត្ត ដូចចែងនៅក្នុងវិធានផ្ទៃក្នុងនោះដែរ ឬទេ"។

## III. ប្រវត្តិនីតិវិធី

9. កាលពីថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ "បន្ទាប់ពីការពិនិត្យលើភស្តុតាងដែលទទួលបានពីសហករណ៍ និងការដ្ឋាននានា មន្ទីរសន្តិសុខ និងទីកន្លែងសម្លាប់មនុស្សនានា" ក.ស.ច.ស បានកំណត់ បទចោទនានាដែលត្រូវបានជូនដំណឹងទៅ នួន ជា នាពេលបង្ហាញខ្លួនជាលើកដំបូង និងសម្រេចថា "នួន ជា ត្រូវស្ថិតក្រោមបទចោទផ្សេងៗទៀត" ហើយអាស្រ័យហេតុនេះ បានចោទគាត់បន្ថែម *ដែលក្នុងចំណោមបទចោទនោះ* មាន "ការរំលោភសេពសន្ថវៈ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចបានកំណត់នៅក្នុងមាត្រា ៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[3]។ ស្រដៀងគ្នានេះដែរ កាលពី

---

[2] ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការបំភ្លឺអំពីបទចោទ, **D198**, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩។

[3] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **D275**, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១១។ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានបញ្ជាក់ឡើងវិញអំពី "កាតព្វកិច្ចរបស់ខ្លួន" ដូចមានចែងនៅក្នុងវិធាន ៥៥(២) នៃវិធានផ្ទៃក្នុង ក្នុងការស៊ើបអង្កេតផ្នែកអង្គហេតុទាំងអស់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (រួមទាំងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម) ដែលបានបញ្ជូនមកខ្លួន។ សូមមើល ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យធ្វើការបំភ្លឺអំពីបទចោទ, **D198**, ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ២០០៩, កថាខណ្ឌ៦។ សហចៅក្រមស៊ើបអង្កេតសម្រេចថា "សហចៅក្រមស៊ើបអង្កេនឹងវិនិច្ឆ័យលើអង្គហេតុទាំងមូលនេះ និងលើការកំណត់ប្រភេទបទល្មើសជាក់ស្ដែងដែលស្នើឡើងដោយសហព្រះរាជអាជ្ញា (ដែលរួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងបទល្មើសជាតិក្នុងក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦)

ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ សហចៅក្រមស៊ើបអង្កេត បានកំណត់ពីបទចោទនានាដែលត្រូវបានជូនដំណឹងនេះ ខៀវ សំផន នាពេលបង្ហាញខ្លួនជាលើកដំបូង ក្នុងនោះមានទាំង "ការរំលោភសេពសន្ថវៈ" ដែលជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[4]។

10. កាលពីថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដោះស្រាយ ដែលមានទាំងការចោទប្រកាន់ផ្នែកអង្គហេតុចំពោះព្រឹត្តិការណ៍នានា នៃការរំលោភសេពសន្ថវៈ នៅមន្ទីរសន្តិសុខ និងនៅតាមសហករណ៍នានា[5]។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតបានសន្និដ្ឋាន ថា៖

> "គោលនយោបាយជាផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ គឺបង្ការបទឧក្រិដ្ឋនេះ និងដាក់ទណ្ឌកម្មដល់ចារី។ ពិតណាស់ ទោះបីជាគោលនយោបាយនេះ មិនអាចឈានទៅដល់ការរារាំងការរំលោភផ្លូវភេទក៏ដោយ ក៏គេមិនអាចចាត់ទុកថា ការរំលោភផ្លូវភេទជាឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រើប្រាស់ដោយបក្សកុម្មុយនីស្តកម្ពុជាក្នុងការដាក់ឱ្យអនុវត្តនូវផែនការរួមឡើយ[6]។

11. នៅក្នុងសេចក្តីសម្រេចបញ្ជប់ ដីកាដំណោះស្រាយ ធ្វើការចោទប្រកាន់លើជនជាប់ចោទទាំងនោះ និងបានដាក់ប្តឹងទៅកាន់អង្គជំនុំជម្រះសាលាដំបូង អំពីការចោទប្រកាន់ឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រង់ផ្នែកការប្រព្រឹត្ត, ការរៀបចំផែនការ, ការញុះញុងឱ្យប្រព្រឹត្ត, ការបញ្ជា, ការជួយ និងការជម្រុញ ឬការទទួលខុសត្រូវក្នុងនាមថ្នាក់លើ[7]។ ទោះបីយ៉ាងណា ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវ បន្ទាប់ពីបានធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនដូចបានលើកឡើងខាងលើនេះ សហចៅក្រមស៊ើបអង្កេតពុំបានចាត់ទុកសហឧក្រិដ្ឋកម្មរួមថា ជា

---

ក្នុងនោះសហចៅក្រមស៊ើបអង្កេតអាចនឹងបញ្ជូនជនត្រូវចោទទៅជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីការដាក់ពួកគេឱ្យឋិតនៅក្រោមការពិនិត្យ ឬចេញដីកាលើកលែងការចោទប្រកាន់ចំពោះអង្គហេតុទាំងមូល ឬដោយផ្នែក"។ (*ដូចខាងលើ* ទំព័រ ៦)។

[4] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **D3/576**, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ ១០។

[5] ដីកាដំណោះស្រាយ, **D437**, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០ ("ដីកាដំណោះស្រាយ"), កថាខណ្ឌ១៤២៦-១៤២៨។

[6] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៩។

[7] ដីកាដំណោះស្រាយ, កថាខណ្ឌ១៦១៣។

ទម្រង់នៃការទទួលខុសត្រូវ ចំពោះការចោទប្រកាន់ឧក្រិដ្ឋកម្មនៃការរំលោភផ្លូវភេទ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំទេ[8]។

12. ពុំមានមេធាវីការពារក្តីក្នុងក្រុមណាមួយ (ជារួម "មេធាវីការពារក្តី") ជំទាស់ទៅនឹងការកត់សម្គាល់ឃើញ*ពីអង្គហេតុ* ដែលទាក់ទងនឹងករណីនៃការរំលោភសេពសន្ថវៈដែលរងរងការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬស្នើសុំមោឃភាពទៅលើវិការៈនៃនីតិវិធី ដូចមានចែងនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងឡើយ។ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងដីកាដំណោះស្រាយ មេធាវីការពារក្តី នួន ជា *ក្នុងចំណោមចំណុចនានា* បានប្តឹងឧទ្ធរណ៍លើការកំណត់ទោសព្រហ្មទណ្ឌនៃបទល្មើស ដែលចែងនៅក្នុងមាត្រា ៤-៦ នៃច្បាប់ អ.វ.ត.ក[9]។ មេធាវីការពារក្តី ខៀវ សំផន បានប្តឹងឧទ្ធរណ៍ ដោយលើក

[8] *សូមមើល* ដីកាដំណោះស្រាយ, កថាខណ្ឌ ១៥២៥។ ទាក់ទងនឹងទម្រង់នៃការទទួលខុសត្រូវផ្សេងទៀត ពួកគាត់ស្នើឱ្យការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភផ្លូវភេទ ក្របដណ្តប់ដោយៈ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភផ្លូវភេទ (ដីកាសន្និដ្ឋាន កថាខណ្ឌ ១៤២៦) កម្រិតត្រឹមតែសហករណ៍ត្រាំកក់ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ (បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើទារុណកម្ម (ដីកាដំណោះស្រាយ កថាខណ្ឌ១៥២៥ (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ១៥៤៥ (ការរៀបចំផែនការ), កថាខណ្ឌ១៥៤៨ (ការញុះញុងឱ្យប្រព្រឹត្ត), កថាខណ្ឌ១៥៥១ (ការជួយ និងការជំរុញ), កថាខណ្ឌ ១៥៥៤ (ការបញ្ជា), កថាខណ្ឌ ១៥៥៩ (ការទទួលខុសត្រូវរបស់ថ្នាក់លើ) កម្រិតត្រឹមតែសហករណ៍ត្រាំកក់, ស២១, ក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រោល និងការប្រព្រឹត្តលើជនជាតិចាម (បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៣ និងអំពើអមនុស្សធម៌ដទៃទៀត ត្រង់ផ្នែកការប៉ះពាល់លើសេចក្តីថ្លៃថ្នូរបស់មនុស្សជាតិ (ដីកាសន្និដ្ឋានដំណោះស្រាយ, កថាខណ្ឌ ១៤៣៣-១៤៤៤, កថាខណ្ឌ ១៥២៥ (សហឧក្រិដ្ឋកម្មរួម), កថាខណ្ឌ ១៥៤៥ (ការរៀបចំផែនការ), កថាខណ្ឌ ១៥៥១ (ការជួយ និងការជំរុញ), កថាខណ្ឌ ១៥៥៤ (ការបញ្ជា), កថាខណ្ឌ ១៥៥៩ (ការទទួលខុសត្រូវរបស់ថ្នាក់លើ) កម្រិតត្រឹមតែការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន (ដំណាក់កាលទី២) កម្រិតត្រឹមតែការប្រព្រឹត្តលើជនជាតិចាម, សហករណ៍ត្រាំកក់, ទំនប់ត្រពាំងថ្ម, ទំនប់១មករា និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង និងក្រាំងតាចាន់, អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល (បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤)។

[9] បណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/3/1**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, កថាខណ្ឌ ៣០-៣២, មេធាវីការពារក្តី នួន ជា ធ្វើការជំទាស់បន្ថែមថា ដីកាដំណោះស្រាយ មានកំហុសក្នុងការបញ្ជាក់ពីយុត្តាធិការរបស់សាលាក្តី ដោយសន្និដ្ឋានថាការអនុវត្តចំពោះឧក្រិដ្ឋកម្មអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវ ដែលបានយោងនៅក្នុងច្បាប់ អ.វ.ត.ក ស្រមទៅនឹងគោលការណ៍នីត្យានុកូលភាព(*ដូចដើងទំព័រខាងលើ* កថាខណ្ឌ២៤-២៦), ច្បាប់ព្រហ្មទណ្ឌក្នុងប្រទេសនៅពេលហេតុការណ៍ដែលត្រូវបានចោទ បានកើតឡើង ពុំចែងអំពីការដាក់ជាទោសព្រហ្មទណ្ឌទៅលើអំពើប្រល័យពូជសាសន៍,

ឡើងអំពីការបំពានលើសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌[10]។ កាលពីថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[11] និងសម្រេចថា ការរំលោភផ្លូវភេទ មិនមែនជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ទេ[12] ប៉ុន្តែអាចត្រូវបានកំណត់ថា ជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោមអំពើអមនុស្សធម៌ដទៃទៀត៖

> "មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះ ត្រូវបានអនុញ្ញាតក្នុងវិសាលភាព ដែលសហមេធាវីការពារក្តី អះអាងថា ការរំលោភលើផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេក្នុងរយៈពេលពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩។ ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចដកការរំលោភផ្លូវភេទចេញពីកថាខណ្ឌ ១៦១៣ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ កថាខណ្ឌ (ឆ) នៃដីកាដំណោះស្រាយ និងរក្សាទុកការយល់ឃើញរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងកថាខណ្ឌ ១៤៣៣ នៃដីកាដំណោះស្រាយថា "អង្គហេតុដែលត្រូវបានកំណត់ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ក្រោម

---

ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬឧក្រិដ្ឋកម្មសង្គ្រាមឡើយ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ២៧-២៩)។ គោលការណ៍នីត្យានុកូលភាព អន្តរជាតិ ពុំចែងអំពីឧក្រិដ្ឋភាពនៅក្នុងប្រទេសឡើយ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៣-៣៤)។ ការដាក់ជាទោសព្រហ្មទណ្ឌដោយប្រតិសកម្ម រំលោភទៅលើគោលការណ៍នីត្យានុកូលជាតិ (*ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៣៥-៣៧)។

[10] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/3**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០, កថាខណ្ឌ ៣១-៣៧។ ក្រុមមេធាវីការពារក្តី ខៀវ សំផន ក៏បានលើកឡើងអំពីបញ្ហានានាទាក់ទងនឹងការបដិសេធសិទ្ធិឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ពាពរ (៦៣-៥៨) ភ័ស្តុតាងពុំមានជាភាសាបារាំង និងភាសាខ្មែរ (៦៩-៧៣), កង្វះតម្លាភាពនៃសកម្មភាពរបស់សហចៅក្រមស៊ើបអង្កេត (៧៤-៨៤) និងកិច្ចស៊ើបសួរមិនបានពេញលេញ និងដោយអន្លើ (៨៥-១១៨)។

[11] ក្រុមមេធាវីការពារក្តី អៀង សារី និង អៀង ធីរិទ្ធ ជំទាស់ថាការរំលោភផ្លូវភេទ ពុំបានកើតឡើងជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។ *សូមមើល* បណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/6**, ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១០, បណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/1**, ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១០។

[12] អង្គបុរេជំនុំជម្រះ យល់ឃើញថា "ការរំលោភសេពសន្ថវៈ គឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមានធាតុផ្សំទាំងអស់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ដូចជាលក្ខខណ្ឌតម្រូវដែលជាផ្នែកមួយនៃ "ការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ" និង "ការរំលោភលើផ្លូវភេទដែលច្បាប់ព្រហ្មទណ្ឌថ្នាក់ជាតិ កំណត់និយមន័យ មិនមានធាតុផ្សំនេះទេ" និងលើកឡើងបន្ថែមថា "ការរំលោភលើផ្លូវភេទតែឯកឯង មិនអាចបញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានទេ ដោយសារគោលការណ៍ទូទៅរបស់ច្បាប់ ដែលត្រូវបានទទួលស្គាល់ដោយបណ្តាប្រជាជាតិដែលមានអារ្យធម៌ខ្ពង់ខ្ពស់" និង*សូមមើល* សាលដីកាលើបណ្តឹងឧទ្ធរណ៍ ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/3/15**, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ១៥៣។

ទម្រង់ជាការរំលោភផ្លូវភេទ អាចត្រូវបានកំណត់ជាលក្ខណៈបន្ទាប់បន្សំថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបង្កឡើងពីអំពើអមនុស្សធម៌ដទៃទៀត)[13]"។

13. កាលពីថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញា បានដាក់សំណើឱ្យអង្គជំនុំជម្រះសាលាដំបូងកំណត់សារជាថ្មីនូវអង្គហេតុនានា ដែលបញ្ជាក់ពីការប្រព្រឹត្តិអំពើរំលោភផ្លូវភេទថា ជាបទរំលោភផ្លូវភេទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ[14]។ ជាការឆ្លើយតប សហមេធាវីនាំមុខ ក៏បានស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យកំណត់អំពីការរំលោភផ្លូវភេទ សារជាថ្មី ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ "ស្របទៅតាមលក្ខណៈរបស់វា"[15]។

14. កាលពីថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង ដែលបានចេញសេចក្តីសម្រេចរបស់ខ្លួនលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/២ ដាក់បញ្ចូលយ៉ាងច្បាស់នូវបទចោទនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត ត្រង់ផ្នែកការរំលោភសេពសន្ថវៈ ដែលកម្រិតត្រឹមតែនៅសហករណ៍ត្រាំកក់ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់ និងក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[16]។ សេចក្តីសម្រេចនេះ ក៏ដាក់បញ្ចូលផងដែរនូវបទចោទនៃអំពើអមនុស្សធម៌ដទៃទៀត ត្រង់ផ្នែក "ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ" ដែលកម្រិតត្រឹមតែនៅសហករណ៍ត្រាំកក់ ទំនប់

---

[13] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/12**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១១(២), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/26**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៧(២)។ *សូមមើលផងដែរ* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/14**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២(១២)។

[14] សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យអង្គជំនុំជម្រះសាលាដំបូង កំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពស្ថវៈ នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, **E99**, ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១, កថាខណ្ឌ ៣៣។

[15] ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកំណត់បទចោទសាជាថ្មីទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ, **E99/1**, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១១, កថាខណ្ឌ ៤៥(១)។

[16] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤។

ត្រពាំងថ្ម ទំនប់១មករា ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង សង្កាត់២១ ក្រាំងតាចាន់ អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល[17] ព្រមទាំងការធ្វើទារុណកម្ម ដែលកម្រិតត្រឹមតែសហាករណ៍ត្រាំកក់ សង្កាត់២១ ក្រាំងតាចាន់ មន្ទីរសន្តិសុខភ្នំក្រោល និងការប្រព្រឹត្តិលើជនជាតិចាម[18]។

15. កាលពីថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង បានសម្រេចថា អង្គជំនុំជម្រះពុំមានសិទ្ធិអំណាចដាក់បញ្ចូលអង្គហេតុ ឬបទចោទថ្មីទៅក្នុងដីកាដំណោះស្រាយ ដែលអង្គហេតុ ឬបទចោទនោះ ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេត ហើយដែលអង្គបុរេជំនុំជម្រះ[19] ពុំមានជំហរផ្សេងពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតនោះទេ ជាពិសេសទាក់ទងនឹង "ការរំលោភផ្លូវភេទជា*គោលនយោបាយ*មួយ នៅក្នុងមន្ទីរសន្តិសុខ"[20]។ នៅក្នុងសេចក្តីសម្រេចដដែលនោះ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូង រក្សាសិទ្ធិ "ផ្លាស់ប្តូរការកំណត់បទចោទដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបាន លុះត្រាតែ*មិនមានការដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទ*"[21]។

## IV. កិច្ចពិភាក្សា

16. កាលពីថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦ ផ្អែកលើអនុស្សរណៈស្តីពីព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់ សហព្រះរាជអាជ្ញាអន្តរជាតិ បានកត់សម្គាល់ថា "សហព្រះរាជអាជ្ញាមិនពិចារណាលើភ័ស្តុតាងណា ដែលកម្មាភិបាលត្រូវបានគេផ្តន្ទាទោសចំពោះអំពើរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ថាជាភ័ស្តុតាងដោះបន្ទុកនោះទេ ពីព្រោះថា *ដីកាដំណោះស្រាយមិនបានចោទប្រកាន់ជនជាប់ចោទនឹងបទល្មើសរំលោភភេទ ដែលបានប្រព្រឹត្តក្រៅវិសាលភាពនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំឡើយ*"[22]។

---

[17] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង០០២/០២, **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤។

[18] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង០០២/០២, **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៣។

[19] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, **E301/0/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, កថាខណ្ឌ ៣។

[20] *ដូចជើងទំព័រខាងលើ* (គូសបញ្ជាក់បន្ថែម)។

[21] *ដូចជើងទំព័រខាងលើ*។

[22] ការដាក់បង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិនូវឯកសារមួយចំនួនពីសំណុំរឿង០០៤ ដែលពាក់ព័ន្ធនឹងសំណុំរឿង០០២ អនុលោមតាមសំណុំរឿង០០៤ D193/61, **D319/40**, ថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៦, កថាខណ្ឌ ៦ *ដកស្រង់* ព័ត៌មានបន្ថែម

17. ទាក់ទងនឹងដំហររបស់សហព្រះរាជអាជ្ញា និងអានុភាពនៃច្បាប់ដែលពាក់ព័ន្ធ សហមេធាវីនាំមុខស្នើសុំការបំភ្លឺពីអង្គជំនុំជម្រះសាលាដំបូង អំពីវិសាលភាពនៃការចោទប្រកាន់អំពីឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដូចបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ។

**(ក) អង្គជំនុំជម្រះសាលាដំបូងកំពុង និងបន្តទទួលបណ្ដឹងអំពីការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ**

18. សហមេធាវីនាំមុខកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតពុំបានច្រានចោលការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភផ្លូវភេទទេ។ ការកត់សម្គាល់នេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់ ដោយផ្អែកលើសំអាងហេតុមួយចំនួន។ ទីមួយ សហចៅក្រមស៊ើបអង្កេត ពុំបានប្រើប្រាស់ពាក្យពេចន៍ច្បាស់លាស់ ដែលឈានទៅដល់ការចេញដីកាលើកលែងការចោទប្រកាន់ យោងតាមខ្លឹមសារនៅក្នុងវិធាន ៦៧(៣) នៃវិធានផ្ទៃក្នុងទេ។

19. ទីពីរ សហចៅក្រមស៊ើបអង្កេត បានកម្រិតពាក្យពេចន៍នៅក្នុងដីកាដំណោះស្រាយ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានថា ការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភផ្លូវភេទ និងភ័ស្តុតាងដែលពាក់ព័ន្ធក្នុងដំណាក់កាលនោះ មិនអាចចាត់ទុកថាជា "ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រើប្រាស់ដោយមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា ក្នុងការអនុវត្តគោលបំណងរួម"ដែលទំនងជាមានបំណងលើកឡើងនូវសហឧក្រិដ្ឋកម្មរួម ថាជា*ទម្រង់* មួយនៃការទទួលខុសត្រូវ ជាជាងលក្ខណៈសម្បត្តិរបស់វាជាឧក្រិដ្ឋកម្មដ៏សំខាន់មួយ[23]។

---

ទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, **E306**, ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០១៤, កថាខណ្ឌ ៣ (គូសបញ្ជាក់បន្ថែម)។ មុននេះ កាលពីថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ សហព្រះរាជអាជ្ញា ជាការឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដី នួន ជា ដែលស្នើឲ្យដាក់បន្ថែមសាក្សីចំនួន១៥រូប សម្រាប់ផ្នែកស្ដីពីសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ បានថ្លែងថា "មេធាវីការពារក្ដី បានលើកឡើងជាច្រើនអំពីការជំទាស់ដែលបានធ្វើឡើងទាក់ទងនឹងថាតើមនុស្សម្នាក់ក្នុងចំណោមអ្នកទាំងនេះគឺជនរងគ្រោះដោយសារអំពើហិង្សាផ្លូវភេទដែរឬទេ។ ខ្ញុំសូមរំឮកអ្នកគ្រប់គ្នាថាដោយហេតុថាវាជាបញ្ហាដែលជាប់ទាក់ទងនោះ ជនជាប់ចោទ មិនត្រូវបានចោទទៅលើការរំលោភផ្លូវភេទនេះទេ។ យើងបានឃើញពួកគាត់ចំណាយពេលជាច្រើនសាកសួរសាក្សីអំពីបញ្ហានេះ ជនជាប់ចោទ មិនត្រូវបានចោទទៅលើការរំលោភផ្លូវភេទនេះទេ។ ពួកគេត្រូវបានចោទពីអំពើមនុស្សឃាត។ ដូច្នេះ ខ្ញុំយល់ឃើញថាក្នុងការសម្រេចថាតើយើងនឹងស្ដាប់សក្ខីកម្មសាក្សី គឺអាស្រ័យលើការពិចារណារបស់អង្គជំនុំជម្រះ"។ *សូមមើល* ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥, **E1/289.1**, ទំព័រ៨៣-៨៤។

[23] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៩។

20. ទីបី ប្រសិនបើមានការចេញដីកាលើកលែងការចោទប្រកាន់ណាមួយទាក់ទងនឹងបញ្ហានេះ នោះនឹងបណ្តាលឲ្យសហព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណី អនុវត្តសិទ្ធិដាក់បណ្តឹងឧទ្ធរណ៍ជំទាស់នឹងការលើកលែងការចោទប្រកាន់នោះជាមិនខាន[24]។ ករណីនេះ ពុំបានកើតឡើងទេ។

21. ដូច្នេះ សហមេធាវីនាំមុខ សន្និដ្ឋានថា ដីកាដំណោះស្រាយ បានប្តឹងអង្គជំនុំជម្រះសាលាដំបូងអំពីការចោទប្រកាន់ផ្នែកអង្គហេតុនានានៃការប្រព្រឹត្ត ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈ នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងស២១[25]។ ដីកាដំណោះស្រាយ ស្នើឲ្យធ្វើការកំណត់ការរំលោភសេពសន្ថវៈថាជាសកម្មភាពអមនុស្សធម៌ដទៃទៀត ដោយសារតែការរំលោភផ្លូវភេទ[26] ជាសកម្មភាពអមនុស្សធម៌ដទៃទៀតនេះ ធ្វើឲ្យ "ការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ"[27] និងអាចកំណត់ប្រភេទជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិលើផ្នែកការធ្វើទារុណកម្ម[28]។ ដូចបានលើកឡើងខាងលើរួចហើយ ចំណុចទាំងនោះ ត្រូវបានដាក់បញ្ចូលយ៉ាងច្បាស់នៅក្នុងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/២[29]។

22. សហមេធាវីនាំមុខសន្និដ្ឋានថា ជនជាប់ចោទទាំងពីរ ត្រូវបានជូនដំណឹងយ៉ាងសមស្របអំពីបទចោទនៃការរំលោភសេពសន្ថវៈ ហើយជនជាប់ចោទទាំងពីរ ទទួលបានការជូនដំណឹងនេះ ចាប់តាំងពីឆ្នាំ ២០០៩ មកម្ល៉េះ[30]។ បន្ទាប់មកពីបានធ្វើការស៊ើបអង្កេតលើអង្គហេតុនៃការប្រព្រឹត្តិអំពើ

---

[24] វិធាន ៦៧(៣), ៧៤ នៃវិធានផ្ទៃក្នុង, មាត្រា ២៤៧, ២៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

[25] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៦-១៤៣៣ *សូមអានជាមួយ* បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៤។

[26] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤២៦-១៤៣៣ កម្រិតត្រឹមតែសហករណ៍ត្រាំកក់ ស២១ និងមន្ទីរសន្តិសុខក្រាំងតាចាន់។

[27] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤៣៤-១៤៤១ កម្រិតត្រឹមតែការផ្លាស់ប្តូរទីលំនៅរបស់ប្រជាជន (ដំណាក់កាលទី២) (កម្រិតត្រឹមតែការប្រព្រឹត្តលើជនជាតិចាម), សហករណ៍ត្រាំកក់, ទំនប់ត្រពាំងថ្ម, ទំនប់១មករា និងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង និងក្រាំងតាចាន់, អូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល។

[28] ដីកាដំណោះស្រាយ, កថាខណ្ឌ ១៤០៨-១៤១៤ កម្រិតត្រឹមត សហករណ៍ត្រាំកក់, ស២១, ក្រាំងតាចាន់, មន្ទីរសន្តិសុខភ្នំក្រោល និងការប្រព្រឹត្តិលើជនជាតចាម។

[29] បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ ៣-៤។

[30] កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **D275**, ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ១១។ កំណត់ហេតុនៃការសួរចម្លើយជនត្រូវចោទ, **E3/576**, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩, កថាខណ្ឌ១០។

រំលោភសេពសន្ថវៈ ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ សហចៅក្រមស៊ើបអង្កេតបានដាក់បញ្ចូលអង្គហេតុទាំងនេះទៅក្នុងដីកាដំណោះស្រាយ។ អង្គហេតុ និងបទចោទទាំងនេះ ត្រូវបានប្តឹងឧទ្ធរណ៍ ហើយត្រូវបានអង្គបុរេជំនុំជម្រះ*តម្កល់* ការចោទប្រកាន់ជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយ នៃបទចោទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការរំលោភសេពសន្ថវៈ[31]។

**(ខ) អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចធ្វើការសម្រេច ផ្នែកច្បាប់លើការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ**

23. សហមេធាវីនាំមុខយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ចធ្វើការពិចារណាលើការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ ដែលត្រូវបានបញ្ជូនឲ្យមកជំនុំជម្រះ, ជូនដំណឹងឲ្យបានសមស្របដល់ជនជាប់ចោទ និងបង្ហាញពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទម្នាក់ៗ ឲ្យបានសមស្របបំផុត។ អនុលោមតាមវិធាន ៩៨(២)-(៣) នៃវិធានផ្ទៃក្នុង ដីកាដំណោះស្រាយ និងសេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/២[32] អង្គជំនុំជម្រះសាលាដំបូង មានកាតព្វកិច្ច ធ្វើសេចក្តីសម្រេចទាក់ទងនឹងការទទួលខុសត្រូវរបស់ជនជាប់ចោទលើបទចោទ យ៉ាងហោចណាស់ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រង់ផ្នែកអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការរំលោភសេពសន្ថវៈនេះ[33]។

---

[31] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/12**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១១(២), សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/26**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៧(២)។ *សូមមើលផងដែរ* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/14**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២(១២)។

[32] សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាព ០០២/២, **D301/9/14**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ("សេចក្តីសម្រេចលើលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាព ០០២/២")។ *សូមមើលផងដែរ* បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤។

[33] ដីកាដំណោះស្រាយ, កថាខណ្ឌ១៤២៦-១៤៣៣ *សូមអានជាមួយ* បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ទំព័រ៥។

24. លើសពីនេះ សហមេធាវីការពារក្តីយល់ឃើញថា អង្គជំនុំជម្រះសាលាដំបូង មិនជាប់កាតព្វកិច្ចក្នុងការអនុវត្តតាមការកំណត់បទចោទ ដែលស្នើឡើងដោយសហចៅក្រមស៊ើបអង្កេតទេ[34]។ អង្គជំនុំជម្រះសាលាដំបូង *អាច*ជ្រើសរើសធ្វើការពិចារណាលើបទចោទ នៅពេលដែលខ្លួនធ្វើសេចក្តីសន្និដ្ឋានផ្អែកលើភស្តុតាងដែលដាក់នៅចំពោះមុខ។ ដូច្នេះ ចំពោះលក្ខណៈច្បាប់ដែលនៅសេសសល់ទាក់ទងនឹងឧក្រិដ្ឋកម្មនៃការរំលោភសេពសន្ថវៈ ដីកាដំណោះស្រាយ ផ្តល់ឆន្ទានុសិទ្ធបន្ថែមដល់អង្គជំនុំជម្រះសាលាដំបូង ដើម្បីធ្វើការពិចារណាដាក់បញ្ចូលបទចោទទៅក្នុងវិសាលភាពនៃ "អំពើអមនុស្សធម៌ដទៃទៀត ត្រង់ផ្នែក "ការប៉ះពាល់លើសេចក្តីថ្លៃថ្នូរបស់មនុស្ស"" និង/ឬ "ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រង់ផ្នែកអំពើទារុណកម្ម"។

25. ឆន្ទានុសិទ្ធិនេះ ក៏ពន្លាតទៅដល់ការជ្រើសរើស និងការកំណត់ទម្រង់នៃការទទួលខុសត្រូវ និងការកត់សម្គាល់ឃើញបទល្មើសសំខាន់ៗដែលពាក់ព័ន្ធ[35]។ បម្រាមតែមួយគត់ក្នុងការអនុវត្តឆន្ទានុសិទ្ធិនេះ គឺថាអង្គជំនុំជម្រះសាលាដំបូង ពុំអាចធ្វើការកំណត់បទចោទនៃឧក្រិដ្ឋកម្ម ដែលមានការដាក់បញ្ចូលនូវធាតុផ្សំថ្មីនៃបទចោទឡើយ[36]។

26. សហមេធាវីនាំមុខសន្និដ្ឋានថា ការសម្រេចថាតើអង្គហេតុ ឬភស្តុតាងទាំងនោះ អាចចាត់ទុកជាការរំលោភសេពសន្ថវៈ ដែលជាឧក្រិដ្ឋកម្មមួយ ឬយ៉ាងណា គឺជាការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ នៅពេលធ្វើការវាយតម្លៃលើភស្តុតាងទាំងមូល នៅក្នុងដំណាក់កាលនៃការចេញសេចក្តីសម្រេច។ រហូតដល់ពេលនោះ ទោះបីជាភាគីនានាមានជំហរបែបណាក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូង មានឆន្ទានុសិទ្ធិក្នុងការជំនុំជម្រះលើភស្តុតាង ទាក់ទងនឹងការប្រព្រឹត្តអំពើរំលោភសេពសន្ថវៈ នៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/២ និងមានកាតព្វកិច្ចធ្វើសេចក្តីសម្រេចលើការកត់សម្គាល់អំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស។

**(គ) សេចក្តីសន្និដ្ឋាន**

27. អាស្រ័យហេតុនេះ តាមរយៈសារណានេះ សហមេធាវីនាំមុខស្នើសុំការបញ្ជាក់បំភ្លឺពីអង្គជំនុំជម្រះសាលាដំបូងថាតើអង្គជំនុំជម្រះសាលាដំបូង ទទួលបណ្តឹងអំពីការចោទប្រកាន់ផ្នែកអង្គហេតុនៃការ

---

[34] ព័ត៌មានបន្ថែមទាក់ទងនឹងអញ្ញត្រកម្មដែលនៅសេសសល់, **E306**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, កថាខណ្ឌ ៣។

[35] សូមមើល ដីកាដំណោះស្រាយ កថាខណ្ឌ ១៥២១-១៥៦០។

[36] *ដូចជើងទំព័រខាងលើ*។

រំលោភសេពសន្ថវៈ និងឧក្រិដ្ឋកម្មដែលត្រូវបានបញ្ជូនមកជំនុំជម្រះយ៉ាងសមស្រប នៅក្នុងវិសាលភាពនៃសំណុំរឿង ០០២/២ និងនៅបន្តពិចារណាលើការចោទប្រកាន់ផ្នែកអង្គហេតុទាំងនោះដែរ ឬទេ បើទោះបីជាវាពុំមែនជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើរំលោភលើផ្លូវភេទទេនោះ[37]។

## V. សំណើ

28. ដោយកត់សម្គាល់ឃើញថា (១) ជនជាប់ចោទ ត្រូវបានចោទប្រកាន់ជាផ្លូវការនូវផ្នែកអង្គហេតុនៃការរំលោភសេពសន្ថវៈ និងបទចោទដែលបានស្នើឡើង (២) ពុំមានការច្រានចោលបទចោទនៃការរំលោភសេពសន្ថវៈ នៅក្នុងដីកាដំណោះស្រាយ (៣) សេចក្ដីសម្រេចបញ្ចប់នៃដីកាដំណោះស្រាយបានដាក់បញ្ចូលការរំលោភសេពសន្ថវៈជាឧក្រិដ្ឋកម្មប្រឆាំងនឹមនុស្សជាតិ[38] និង (៤) ឧបសម្ព័ន្ធនៅក្នុងសេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាព នៃសំណុំរឿង០០២/២ ដាក់បញ្ចូលការចោទប្រកាន់ផ្នែកអង្គហេតុនេះ សហមេធាវីនាំមុខ សូមស្នើដោយក្ដីគោរពឲ្យ៖

ក. អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្ដឹងជាផ្លូវការនូវការចោទប្រកាន់ផ្នែកអង្គហេតុនៃការរំលោភផ្លូវភេទ នៅសហករណ៍ត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងសំណុំរឿង ០០២/២ និង

ខ. ចាត់វិធានការណាមួយ ដែលត្រូវបានអនុញ្ញាតដោយវិធានផ្ទៃក្នុង ក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

---

[37] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អៀង ធីរិទ្ធ និង នួន ជា ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/2/12**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ១១(២), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/1/26**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ៧(២)។ *សូមមើលផងដែរ* សាលដីការបស់អង្គបុរេជំនុំជម្រះលើបណ្ដឹងឧទ្ធរណ៍របស់ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ, **D427/4/14**, ថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១, កថាខណ្ឌ ២(១២)។ *សូមមើលផងដែរ* បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿង ០០២/០២), **E301/9/1.1**, ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤, ជើងទំព័រ ១៥។

[38] ក្រោយមក ត្រូវបានអង្គបុរេជំនុំជម្រះធ្វើមោឃភាព ដោយសម្រេចថាជាឧក្រិដ្ឋកម្មដាច់ដោយឡែកមួយ ប៉ុន្តែបានបើកចំហរឲ្យអង្គជំនុំជម្រះសាលាដំបូង កំណត់សាជាថ្មីនូវការរំលោភលើផ្លូវភេទជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ដទៃទៀត, ការប៉ះពាល់លើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ និងការធ្វើទារុណកម្ម។

សូមដាក់ជូនសារណានេះដោយគោរពពី៖

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ | ពេជ អង្គ<br>សហមេធាវីនាំមុខ | ភ្នំពេញ | |
| | Marie GUIRAUD<br>សហមេធាវីនាំមុខ | ភ្នំពេញ | |